នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Dec-2012, 15:47
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងចម្លើយតបរបស់ នួន ជា ចំពោះបណ្តឹងសាទុក្ខប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះតុលាការកំពូល:
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA- MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASIINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
អៀង សារី
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក គង់ សំអុន
លោក Anta GUISSE

លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្តីផ្តើម

១- សហព្រះរាជអាជ្ញាដាក់ជូនការឆ្លើយតបដូចខាងក្រោមនេះ ចំពោះចម្លើយតបរបស់ នួន ជា ទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១(“ចម្លើយតប”)[1]។ ខណៈដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យមានសវនាការផ្ទាល់មាត់មួយ ឬជាជំនួស សុំការអនុញ្ញាតដើម្បីដាក់ការឆ្លើយតបរួមទៅនឹងចម្លើយតបរបស់ជនជាប់ចោទទាំងបីរូប[2] អង្គជំនុំជម្រះតុលាការកំពូលនៅមិនទាន់បានធ្វើការសម្រេចសំណើនោះនៅឡើយទេ។ ហេតុដូចនេះ សហព្រះរាជអាជ្ញាដាក់ការឆ្លើយតបនេះ ដើម្បីធានាឱ្យប្រាកដថាសហព្រះរាជអាជ្ញាមិនលះបង់សិទ្ធិរបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងចម្លើយតប ដែលបានដាក់ដោយមេធាវីការពារក្តីរបស់ នួន ជា ឡើយ[3]។

## II. បណ្តឹងសាទុក្ខនេះ អាចទទួលយកបាន

២- ដូចដែលចម្លើយតបគ្មានអ្វីខុសប្លែកពីអំណះអំណាងទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្តឹងសាទុក្ខ ជាជាងអំណះអំណាងរបស់មេធាវីការពារក្តី អៀង សារី សហព្រះរាជអាជ្ញានឹងមិនលើកឡើងច្រំដែលនូវអំណះអំណាងដែលបានធ្វើឡើងរួចហើយ នៅក្នុងការឆ្លើយតបនាពេលថ្មីៗនេះរបស់ខ្លួនទៅនឹងចម្លើយតបរបស់ អៀង សារី ឡើយ[4]។

---

[1] ឯកសារលេខ **E 163/5/1/4** សារណាឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាទាក់ទិននឹងវិសាលភាពនៃការជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១, ចុះថ្ងៃទី១៩ វិច្ឆិកា ២០១២ (“ចម្លើយតប”)។

[2] ឯកសារលេខ **E163/5/1/6** សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យធ្វើសវនាការផ្ទាល់មាត់ជាសាធារណៈលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចទាក់ទងនឹងនឹងវិសាលភាពនៃការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១ ឬជាជំនួស ស្នើសុំឱ្យដាក់ការឆ្លើយតបរួមមួយទៅនឹងចម្លើយតបរបស់ជនជាប់ចោទទាំងបីនាក់, ចុះថ្ងៃទី២១ វិច្ឆិកា២០១២។

[3] ចម្លើយតបរបស់ នួន ជា ត្រូវបានជូនដំណឹងជាភាសាអង់គ្លេស ចុះថ្ងៃទី២០ វិច្ឆិកា ២០១២ និងជាភាសាខ្មែរ ចុះថ្ងៃទី២៦ វិច្ឆិកា ២០១២, ដូចនេះ ការឆ្លើយតបទៅនឹងចម្លើយតបនោះគឺត្រូវដល់ថ្ងៃកំណត់នៅថ្ងៃទី០៣ ធ្នូ ឆ្នាំ២០១២។ ចម្លើយតបរបស់ក្រុមមេធាវីការពារក្តីរបស់ ខៀវ សំផន មិនទាន់ដល់ពេលកំណត់នៅឡើយលុះត្រាតែដល់ថ្ងៃទី៣០ វិច្ឆិកា ២០១២ ហើយត្រូវបានជូនដំណឹងជាភាសាខ្មែរ និងបារាំងនៅថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២។

[4] *សូមមើល* **E163/5/1/8** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ចំពោះចម្លើយតបរបស់ អៀង សារី ទៅនឹងសេចក្តីសម្រេចស្តីពីវិសាលភាពនៃការជំនុំជម្រះក្តី នៅក្នុងសំណុំរឿងលេខ០០២/០១, ២៦ វិច្ឆិកា ២០១២។

៣- ទោះជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាធ្វើការកត់សម្គាល់ឃើញថា ភាពផ្ទុយគ្នាស្រឡះទៅនឹងអំណះអំណាងនៅក្នុងចម្លើយតបរបស់ខ្លួនដែលថា "កិច្ចដំណើរការនីតិវិធីជាបន្តក្នុងសំណុំរឿង០០២ពិតជាអាចធ្វើទៅបាន ហើយទទួលយកបានទៀតផង"[5] ចំណែកសេចក្តីថ្លែងការណ៍ពីមុនរបស់មេធាវីការពារក្តី នួន ជា ស្តីពីបញ្ហានេះ មានន័យច្បាស់លាស់ស្របជាមួយនឹងគោលជំហររបស់សហព្រះរាជអាជ្ញា។ បន្ថែមទៅលើសេចក្តីថ្លែងការណ៍ពីមុនចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១២ របស់ខ្លួនដែលថ្លែងថា "គ្រប់គ្នាយល់ស្រប" ថានឹង "គ្មាន" ការជំនុំជម្រះក្តីណាផ្សេងទៀតឡើយក្នុងសំណុំរឿង០០២[6]នោះ មេធាវីការពារក្តី នួន ជា បានបញ្ជាក់អះអាងក្នុងកាលៈទេសៈផ្សេងទៀតជាច្រើនលើកច្រើនសារ នូវការយល់ស្របរបស់ខ្លួនជាមួយសហព្រះរាជអាជ្ញាថា ការសង្ឃឹមថានឹងមានការជំនុំជម្រះក្តីជាលើកទីពីរ គឺនៅឆ្ងាយណាស់"[7]។ មេធាវីការពារក្តី មិនអាចបង្វែរគោលជំហររបស់ខ្លួននៅលើកបញ្ហានេះនៅពេលនេះ ដោយគ្រាន់តែធ្វើឲ្យត្រូវទៅនឹងអំណះអំណាងនាពេលនេះដែលខ្លួនមានបំណង ដើម្បីពន្លឿនដល់ការប្រឆាំងទៅនឹងបណ្តឹងសាទុក្ខនេះ។

៤- លើសពីនេះ សេចក្តីថ្លែងកាណ៍របស់មេធាវីការពារក្តី ដែលថាសេចក្តីសម្រេចដែលរងការជំទាស់នេះ "មានអានុភាពដល់*ការពន្យារពេល* នៅក្នុងការធ្វើសេចក្តីសម្រេចអំពីថាតើត្រូវចោទប្រកាន់ចំពោះអង្គហេតុនានាជុំវិញមន្ទីរស-២១ និងស្រុក១២ នៅដំណាក់កាលក្រោយៗទៀតដែរ ឬអត់"[8] គឺមានតម្លៃស្មើនឹងការទទួលយកថា សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង គឺសមមូលនឹងការផ្អាកកិច្ចដំណើរការនីតិវិធីដោយគ្មានកំណត់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មមន្ទីរស-២១ និងស្រុក១២។

## III. សេចក្តីសម្រេចដែលរងការជំទាស់នេះផ្អែកលើកំហុសឆ្គងខាងអង្គហេតុ និងអង្គច្បាប់ ហើយបង្កើតបានជាការបំពានឆន្ទានុសិទ្ធិ

---

[5] **E163/5/1/4** ចម្លើយតប, កថាខណ្ឌ៤។

[6] **E1/136.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ២២ តុលា ២០១២, ទំព័រ៩ (បន្ទាត់៣-១១)។

[7] **E1/114.2** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី: កិច្ចប្រជុំរៀបចំសវនាការ, ២៧ សីហា ២០១២, ទំព័រ២៤-២៥។ **E1/135.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ១៩ តុលា ២០១២, ទំព័រ៤២ ( "យើងសូមបញ្ជាក់ច្បាស់នូវការយល់ស្របរបស់យើងទាំងស្រុងជាមួយអ្វីដែលលោក Cayley បានមានប្រសាសន៍លើបញ្ហានោះកាលពីពេលចុងក្រោយនៅពេលគាត់នៅក្នុងតុលាការ នោះគឺជាអ្វីដែលមិនធ្លាប់កើតមានទាល់តែសោះ")។

[8] **E163/5/1/4** ចម្លើយតប, កថាខណ្ឌ៥។

## ក. អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តបទដ្ឋានច្បាប់មិនត្រឹមត្រូវ ហើយខកខានមិនបានពិចារណាឲ្យបានត្រឹមត្រូវពីផលវិបាកនៃការបំបែកកិច្ចដំណើរការនីតិវិធី

៥- មេធាវីការពារក្តីចាប់ផ្តើមនូវការតវ៉ាជាសារធាតុរបស់ខ្លួន ដោយកំណត់មិនត្រឹមត្រូវនូវអំណះអំណាងរបស់សហព្រះរាជអាជ្ញាទាក់ទងនឹង "ការបង្ហាញសមហេតុផល" ថាជា "មូលដ្ឋានចំបងសម្រាប់បណ្តឹងសាទុក្ខនេះ"[9]។ តាមពិត អំណះអំណាងនេះគ្រាន់តែជាទឡ្ហីករណ៍មួយក្នុងចំណោមទឡ្ហីករណ៍ជាច្រើននៃបណ្តឹងសាទុក្ខនេះ។ សហព្រះរាជអាជ្ញាអះអាងថា ដោយការខកខានមិនបានពិចារណាឲ្យបានសមស្របណាមួយ អំពីផលវិបាកផ្សេងៗនៃការបំបែកកិច្ចដំណើរការនីតិវិធីចំពោះឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន នោះអង្គជំនុំជម្រះសាលាដំបូងមានកំហុសខាងផ្លូវច្បាប់ និងខកខានមិនបានអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនឲ្យស្របទៅតាម "ផលប្រយោជន៍នៃយុត្តិធម៌" ដូចអ្វីដែលមានចែងនៅក្នុងវិធាន៨៩*ស្ទួន*ពីរឡើយ។ និយាយឲ្យចំ ដូចករណីមួយនេះដែលថាការសង្ឃឹមទុកថាមានសវនាការនៅពេលអនាគតមិនប្រាកដនោះ អង្គជំនុំជម្រះសាលាដំបូងមានកាតព្វកិច្ចពិចារណាថាតើឧក្រិដ្ឋកម្មដែលបានរក្សាទុកនោះ ត្រូវបានបង្ហាញដោយបទឧក្រិដ្ឋដូចដែលបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយនៃសំណុំរឿង00២ ដែរ ឬទេ។ ក្នុងកាលៈទេសៈនេះ អង្គជំនុំជម្រះសាលាដំបូងមានកំហុសឆ្គងដោយបានបន្សល់ទុកឲ្យសហព្រះរាជអាជ្ញា និងជនរងគ្រោះនូវការកាត់បន្ថយទីតាំងឧក្រិដ្ឋកម្មយ៉ាងច្រើនដែលមិនឆ្លុះបញ្ចាំងឲ្យបានគ្រប់គ្រាន់អំពីភាពធ្ងន់ធ្ងរ និងទំហំនៃឧក្រិដ្ឋកម្មដែលជនជាប់ចោទត្រូវបានចោទប្រកាន់តាំងពីដំបូងមកឡើយ។

៦- ចម្លើយតបអះអាងថា "មិនចាំបាច់យកទម្លាប់នៃការអនុវត្តជាអន្តរជាតិទេ" ពីព្រោះអង្គជំនុំជម្រះសាលាដំបូងមានឆន្ទានុសិទ្ធិ ដើម្បីឲ្យមាន "ផលប្រយោជន៍នៃយុត្តិធម៌" តាមវិធាន៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង[10]។ ផ្ទុយទៅវិញ ជាការសំខាន់សម្រាប់អង្គជំនុំជម្រះសាលាដំបូងពិនិត្យមើលទម្លាប់នៃការអនុវត្តជាអន្តរជាតិ សម្រាប់ជាគោលការណ៍ណែនាំអំពីរបៀបអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន និងកត្តាផ្សេងៗត្រូវពិចារណា។ ច្បាប់អន្តរជាតិពាក់ព័ន្ធនឹងការបំបែកិច្ចដំណើរការនីតិវិធីមានចែងកំណត់ក្នុងកថាខណ្ឌទី៣៤ នៃសារណាបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។ វិធាន៧៣*ស្ទួន(ឃ)* របស់

[9] **E163/5/1/4** ចម្លើយតប, កថាខណ្ឌ៧។

[10] **E163/5/1/4** ចម្លើយតប, កថាខណ្ឌ១១។

តុលាការ ICTY មានការពាក់ព័ន្ធដូចគ្នានៅទីនេះដែរ ដែលថាការបំបែកបទឧក្រិដ្ឋបង្កើតបានជាការបញ្ចប់ទាំងស្រុង[11]។

**ខ. អង្គជំនុំជម្រះសាលាដំបូង មានការភាន់ច្រឡំនៅក្នុងការសន្និដ្ឋានថា ចំនួនសាក្សីដែលបានស្នើឡើងដោយភាគី ជាលទ្ធផល អាចនាំឲ្យមានការពន្យារពេលនៃសវនាការ**

៧- អង្គជំនុំជម្រះសាលាដំបូងមានការភាន់ច្រឡំបន្ថែមទៀតត្រឹមកម្រិតណានោះ ដែលខ្លួនបានយកមកពឹងផ្អែកសម្រាប់ការធ្វើសេចក្តីសម្រេចរបស់ខ្លួន ស្តីពីចំនួនសាក្សីដែល "បានស្នើឡើង" ដោយមេធាវីការពារក្តី ឬដោយភាគីផ្សេងៗ[12]។ ជាជាងចំនួនសាក្សីដែលបានស្នើឡើងដោយភាគី អង្គជំនុំជម្រះសាលាដំបូងគួរបានពិចារណាអំពីចំនួនសាក្សីសរុបដែលចាំបាច់ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មបន្ថែម និងចំនួនពេលវេលាដែលសាក្សីទាំងនេះត្រូវបន្ថែមក្នុងពេលវេលាទាំងមូលនៃសវនាការ។ ផ្ទុយនឹងចម្លើយតបនេះ សហព្រះរាជអាជ្ញាមិនតវ៉ាចំពោះភាពចាំបាច់ដែលអង្គជំនុំជម្រះសាលាដំបូង ត្រូវធ្វើសេចក្តីសម្រេចដាច់ស្រេចអំពីសាក្សីម្នាក់ៗដែលខ្លួនចាំបាច់ត្រូវស្តាប់សក្ខីកម្មឡើយ[13]។ ជាងនេះទៀត ជាការគ្រប់គ្រាន់សម្រាប់សហព្រះរាជអាជ្ញាវាយតម្លៃជាទូទៅអំពីចំនួនសាក្សីបន្ថែមដែលចំបាច់។

៨- អំណះអំណាងរបស់មេធាវីការពារក្តីដែលថា អង្គជំនុំជម្រះសាលាដំបូង "ជឿ" ថា ចំនួនសាក្សីជាច្រើនអាចត្រូវការស្តាប់សក្ខីកម្មទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មស្រុក១២ និងមន្ទីរស-២១[14] គឺមិនទទួលបានការគាំទ្រឡើយតាមរយៈកំណត់ហេតុ។ ទាក់ទងនឹងទីតាំងសម្លាប់មនុស្សស្រុក១២ អង្គជំនុំជម្រះ

---

[11] គ្មានកំណត់ហេតុបញ្ជាក់ថា កិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក "បានពិចារណាយ៉ាងសកម្ម" និង "បានបដិសេធយ៉ាងច្បាស់លាស់ដោយគ្មានលាក់លៀម" នូវវិធាន៧៣*ស្ទួន*(ឃ) ដូចមេធាវីការពារក្តីបានអះអាងឡើយ។ សេចក្តីថ្លែងរបស់អង្គជំនុំជម្រះសាលាដំបូងដែលបានលើកយោងដោយមេធាវីការពារក្តី គ្រាន់តែបានអះអាងដោយគ្មានសេចក្តីយោងទៅលើកំណត់ហេតុណាមួយនៃកិច្ចពិភាក្សានៃកិច្ចប្រជុំពេញអង្គ ថាខ្លួន "សម្រេច*គ្រាន់តែ*មិនធ្វើការចម្លងយកតាមវិធាន៧៣*ស្ទួន* របស់តុលាការ ICTY នោះទេ"។ ឯកសារ **E124/7** សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង (ឯកសារ E124/2) និងសំណើសុំពាក់ព័ន្ធនានា ព្រមទាំងឧបសម្ព័ន្ធ, ១៨ តុលា ២០១១, កថាខណ្ឌ ៥ (សង្កត់ន័យបន្ថែមត្រង់អក្សរទ្រេត)។

[12] **E163/5** សេចក្តីជូនដំណឹងស្តីពីសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាដែលស្នើសុំដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែម ទៅក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង00២/0១ (ឯកសារ E163) និងពេលវេលាកំណត់នៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលពាក់ព័ន្ធនឹងច្បាប់ជាលាយលក្ខណ៍អក្សរ, ៨ តុលា ២០១២, កថាខណ្ឌ២។

[13] **E163/5/1/4** ចម្លើយតប, កថាខណ្ឌ១៨។

[14] **E163/5/1/4** ចម្លើយតប, កថាខណ្ឌ១៧, ២២។

សាលាដំបូងបានកំណត់ថា សាក្សី១២រូបដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញានៅក្នុងបញ្ជីសាក្សីដើមរបស់ខ្លួនកាលខែមករា ឆ្នាំ២០១១នោះ គឺ "លើស" ហើយ "ទំនងជាជាន់គ្នា" និងថាចាំបាច់ត្រូវកោះហៅ "ច្រើនបំផុតត្រឹមសាក្សីបន្ថែម៥-៦នាក់ប៉ុណ្ណោះ"[15]។ សហព្រះរាជអាជ្ញាយល់ស្របជាមួយនឹងការកំហិតនេះ ហើយនៅក្នុងឯកសារដែលបានដាក់កាលពីកិច្ចប្រជុំរៀបចំសវនាការ ខែសីហា ឆ្នាំ២០១២របស់ខ្លួននោះ សហព្រះរាជអាជ្ញាបានស្នើសាក្សីប្រាំមួយនាក់ដែលត្រូវផ្តល់សក្ខីកម្មទាក់ទងនឹងទីតាំងសម្លាប់ក្នុងស្រុក១២[16]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់លើសំណើនេះ នៅក្នុងសម័យប្រជុំរៀបចំសវនាការថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២[17] ហើយគ្មានសាក្សីបន្ថែមទៀតត្រូវបានស្នើដោយមេធាវីការពារក្តី ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីឡើយទាក់ទងនឹងទីតាំងនេះ[18]។ ទន្ទឹមនេះ ការលើកឡើងរបស់មេធាវីការពារក្តីដែលថាអង្គជំនុំជម្រះសាលាដំបូងបានកំណត់ថា "ការវាយតម្លៃត្រឹមត្រូវមួយអំពីអង្គហេតុនានានៅស្រុក១២ អាចតម្រូវឲ្យមានយ៉ាងហោចណាស់សាក្សី១២នាក់ ដែលសហព្រះរាជអាជ្ញាបានស្នើឡើងនោះ" គឺជាការថ្លែងមិនត្រឹមត្រូវទាល់តែសោះអំពីសម្តីនោះ[19]។

៩- ទាក់ទងនឹងសាក្សីមន្ទីរស-២១ គោលជំហររបស់អង្គជំនុំជម្រះសាលាដំបូង គិតត្រឹមថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ មានដូចតទៅ៖ "អង្គជំនុំជម្រះសាលាដំបូងមានការយកចិត្តទុកដាក់ក្នុងការអនុញ្ញាតឲ្យមានការពង្រីកតាមសំណើសុំនេះ ប៉ុន្តែ តាមទស្សនៈនៃសក្ខីកម្មរបស់ កាំង ហ្កេកអ៊ាវ មកដល់បច្ចុប្បន្ននេះ (បន្ថែមលើភ័ស្តុតាងអំពីមូលដ្ឋានឧក្រិដ្ឋកម្មទាំងអស់ដែលមានស្រេច នៅចំពោះមុខអង្គជំនុំជម្រះទាក់ទងនឹងប្រធានបទនេះ និងអាចទទួលយកបានតាមបច្ច័យនៃសេចក្តីសម្រេចលេខE96/7) អង្គជំនុំជម្រះមិនជឿថា ខ្លួនចាំបាច់ត្រូវស្តាប់សាក្សី ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមទៀតអំពីឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខស-២១ និងនៅជើងឯកឡើយ។ សាក្សីបន្ថែមទាំងអស់ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញាទាក់ទងនឹងចំណុចនេះ គឺជាអ្នកធ្វើការនៅក្រោមបង្គាប់ កាំង ហ្កេកអ៊ាវ នៅ

---

[15] **E218.1** ឧបសម្ព័ន្ធនៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា "សំណើរបស់សហព្រះរាជអាជ្ញាសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163)," ៣ សីហា ២០១២, កថាខណ្ឌ៩។

[16] **E218/2** សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការនៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១២ (ជាមួយនឹងឧបសម្ព័ន្ធសម្ងាត់ ក), ១៥ សីហា ២០១២, កថាខណ្ឌ១៦។

[17] **E1/114.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធី: កិច្ចប្រជុំរៀបចំសវនាការ, ១៧ សីហា ២០១២, ទំព័រ១២០-១២១។

[18] **E236** បុគ្គលនានាដែលបានស្នើឡើងដោយគូភាគីផ្សេងៗដើម្បីស្តាប់សវនាការនៅពេលជំនុំជម្រះ (ដូចដែលបានធ្វើការទំនាក់ទំនងនៅក្នុង ឬភ្លាមៗបន្ទាប់ពីកិច្ចប្រជុំរៀបចំសវនាការ ទៅកាន់មន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់របស់អង្គជំនុំជម្រះសាលាដំបូង), ២ តុលា ២០១២, កថាខណ្ឌ៦-៧។

[19] **E163/5/1/4** ចម្លើយតប, កថាខណ្ឌ២២។

ក្នុងមន្ទីរសន្តិសុខស-២១ ដូច្នេះមិនអាចមានលទ្ធភាពនឹងបញ្ជាក់អំពីការទទួលខុសត្រូវរបស់ជនជាប់ចោទក្នុងសំណុំរឿង00២/១ ឡើយ”[20]។

១០- សហព្រះរាជអាជ្ញាបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងស្តាប់សក្ខីកម្មរបស់ ឌុច និងសាក្សីចំនួន៤រូបបន្ថែមទៀត រួមមាន “អ្នកជាប់ឃុំឃាំងនៅរស់ម្នាក់, អ្នកសួរចម្លើយម្នាក់, កម្មាភិបាលម្នាក់ដែលទទួលខុសត្រូវយកអ្នកទោសទៅសម្លាប់នៅជើងឯក និងប្រធានអង្គភាពទទួលបន្ទុកឯកសារដែលទទួលខុសត្រូវរក្សាកំណត់ហេតុអ្នកទោសនៅមន្ទីរសន្តិសុខស-២១”[21]ផង។ មេធាវីការពារក្តីរបស់ នួន ជា បានស្នើសាក្សីចំនួន៣១រូប សម្រាប់ទីកន្លែងឧក្រិដ្ឋកម្មនេះ[22]។ ចំពោះមូលហេតុនានាដែលមានចែងនៅក្នុងកថាខណ្ឌទី៦១ ដល់៦៥ នៃសារណាសាទុក្ខរបស់សហព្រះរាជអាជ្ញា មានសាក្សីមួយចំនួនដែលមេធាវីការពារក្តីរបស់ នួន ជា បានស្នើ គឺលើសលប់ហួសហេតុ។ នៅក្នុងចម្លើយតបរបស់ខ្លួន មេធាវីការពារក្តីមិនបានផ្តល់យុត្តិកម្មតាមផ្លូវច្បាប់សម្រាប់សាក្សីមួយចំនួនធំដែលបានស្នើនោះឡើយ និងបន្តគ្រាន់តែអះអាងថា សាក្សីទាំងនោះ គឺចាំបាច់ដើម្បី “សាកភាពទុកចិត្តបានរបស់ ឌុច” ប៉ុណ្ណោះ[23]។

១១- អង្គជំនុំជម្រះសាលាដំបូងមិនបានផ្តល់ការចង្អុលបង្ហាញណាមួយ ដែលថាខ្លួនបានទទួលយកចំនួនលើសលុបនៃសាក្សីនៅស-២១ ដែលបានស្នើឡើងដោយមេធាវីការពារក្តី (ឬបើសិនជាដូច្នោះមែនហេតុអ្វី)នោះឡើយ ឬមួយថាខ្លួនបានពិចារណាឡើងវិញពីគោលជំហររបស់ខ្លួនពីមុន ដែលថាទីកន្លែងឧក្រិដ្ឋកម្មបន្ថែមទៀតអាចត្រូវបានធ្វើសវនាការ ដោយពុំចាំបាច់មានការស្តាប់ចម្លើយសាក្សីមួយចំនួនធំបន្ថែមទៀតនោះទេ។ តាមពិតទៅ មិនមានសមហេតុសមផលទេ សម្រាប់ឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើសេចក្តីសន្និដ្ឋានជាមុនថា គ្រាន់តែចាំបាច់ស្តាប់សក្ខីកម្មរបស់ប្រធានមន្ទីរសន្តិសុខស-២១ ប៉ុណ្ណោះ ហើយបន្ទាប់មក ធ្វើការបដិសេធលើការបន្ថែមទីកន្លែង ដោយសារ “ហានិភ័យនៃការពន្យារ

[20] **E218.1** ឧបសម្ព័ន្ធនៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “សំណើរបស់សហព្រះរាជអាជ្ញាសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង 00២/0១ (ឯកសារ E163),” ៣ សីហា ២0១២, កថាខណ្ឌ១១។

[21] ឯកសារលេខ **E218/2** សេចក្តីជូនដំណឹងស្តីពីគោលជំហររបស់សហព្រះរាជអាជ្ញាលើបញ្ហាសំខាន់ៗដែលនឹងត្រូវពិភាក្សាក្នុងកិច្ចប្រជុំរៀបចំសវនាការ នៅថ្ងៃទី១៧ ខែសីហា ឆ្នាំ២0១២ (ដោយមានឧបសម្ព័ន្ធសម្ងាត់ ក), ថ្ងៃទី១៥ ខែសីហា ឆ្នាំ២0១២, កថាខណ្ឌទី១៨។

[22] ឯកសារលេខ **E236** បុគ្គលនានាដែលភាគីស្នើសុំមកផ្តល់សក្ខីកម្មនៅក្នុងសវនាការ (ដែលភាគីបានទាក់ទងទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងពេល ឬក្រោយពេលកិច្ចប្រជុំរៀបចំសវនាការភ្លាម), ថ្ងៃទី២ ខែតុលា ឆ្នាំ២0១២, កថាខណ្ឌទី៧។

[23] ឯកសារលេខ **E163/5/1/4** ចម្លើយតប, កថាខណ្ឌទី ២0-២១, កំណត់សម្គាល់ជើងទំព័រលេខ២១។ *សូមអានផងដែរ* ឯកសារលេខ **E163/5/1/4.1.1** ឧបសម្ព័ន្ធ I ទៅនឹងចម្លើយតប។

ពេលសវនាការយូរពេក” ដោយពុំមានការពន្យល់ឲ្យបានគ្រប់គ្រាន់ពីមូលដ្ឋាននៃសេចក្តីសន្និដ្ឋានបែបនោះឡើយ។

១២- ដូច្នេះ សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានថា សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ដែលថាការបន្ថែមស្រុក១២ និងស-២១ អាចបណ្តាលឲ្យមានហានិភ័យចំពោះ “ការពន្យារពេលសវនាការយូរពេក” នោះគឺមិនមានសម្អាងហេតុ ឬមានមូលដ្ឋានស្តីពីការសន្និដ្ឋានអង្គហេតុប្រាកដជាខុស។ មូលដ្ឋាននៃកំហុសនេះអាចជាការប៉ាន់ស្មានមិនត្រឹមត្រូវទាំងស្រុងរបស់អង្គជំនុំជម្រះទៅលើចំនួននៃពេលវេលាដែលតម្រូវឲ្យស្តាប់ចម្លើយសាក្សីបន្ថែមទាក់ទងទៅនឹងស្រុក១២ និងស-២១។ នៅក្នុងអនុស្សរណៈរបស់ខ្លួនចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានប៉ាន់ស្មានពីដំបូងថា សាក្សីចំនួន២៣រូប ដែលបានស្នើពីដំបូងដោយសហព្រះរាជអាជ្ញា សម្រាប់ទួលពោធិ៍ជ្រៃ ស្រុក១២ និងស-២១ អាច “ស្មើនឹងការពន្យារពេលដំណើរការនីតិវិធីយ៉ាងហោចណាស់ពី៤ដល់៦ខែដែរ”[24]។ ក្រោយមក អង្គជំនុំជម្រះសាលាដំបូងបានថ្លែងថា បើចំនួនសាក្សីបន្ថែមនោះត្រូវបានកាត់បន្ថយមកនៅត្រឹមចំនួន៨នាក់ ដូចដែលខ្លួនបានលើកស្នើឡើងនោះ សវនាការអាចនៅតែពន្យារពេល “យ៉ាងហោចណាស់ក៏៣ខែដែរ”[25]។

១៣- ដូច្នេះ អង្គជំនុំជម្រះសាលាដំបូងទំនងជាត្រូវបាននាំដោយការសន្និដ្ឋានខុស ចំពោះសាក្សីបន្ថែមម្នាក់ៗដែលខ្លួនត្រូវការស្តាប់ចម្លើយទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនោះ សវនាការមុខជានឹងត្រូវពន្យារពេលយ៉ាងហោចណាស់ក៏មួយសប្តាហ៍ដែរ។ តាមការពិត ដូចដែលបានកើតឡើងដោយការស្តាប់ចម្លើយជាក់ស្តែងចំពោះសាក្សីនានាទាក់ទងនឹងការជម្លៀសប្រជាជនដោយបង្ខំ អង្គជំនុំជម្រះសាលាដំបូងមានលទ្ធភាពអាចបញ្ចប់ការស្តាប់សក្ខីកម្មសាក្សីបែបដូចនេះបាន នៅក្នុងរយៈពេលមួយថ្ងៃ ឬតិចជាងនេះ។ ចាប់ពីពេលនេះតទៅ អង្គជំនុំជម្រះសាលាដំបូងបានស្តាប់សក្ខីកម្មសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន១១នាក់ពាក់ព័ន្ធនឹងការជម្លៀសប្រជាជនដោយបង្ខំលើកទីមួយ និងលើកទីពីរ តែក្នុងរយៈពេលចំនួន៩ថ្ងៃប៉ុណ្ណោះ។ ពេលវេលាដែលបានធ្វើការប៉ាន់ស្មានសម្រាប់សាក្សីទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំដែលសហព្រះរាជអាជ្ញាបានផ្តល់ជូន នៅខែសីហា ឆ្នាំ២០១២

---

[24] ឯកសារលេខ **E218.1** ឧបសម្ព័ន្ធ៖ អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី “សំណើរបស់សហព្រះរាជអាជ្ញាស្នើសុំពង្រីកវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ (ឯកសារ E163)”, ថ្ងៃទី៣ ខែសីហា ឆ្នាំ២០១២, កថាខណ្ឌទី៨។

[25] ឯកសារលេខ **E218.1** *ដដែលដូចមុន* ត្រង់កថាខណ្ឌទី១៧។

បានបង្ហាញយ៉ាងច្បាស់ថាមានលក្ខណៈពិតប្រាកដ និងត្រឹមត្រូវ[26]។ ដោយអនុលោមតាមការប៉ាន់ស្មានដូចគ្នានេះ សាក្សីដែលបានស្នើឡើងចំនួន៦រូបសម្រាប់ស្រុក១២ អាចត្រូវការពេលវេលាតែ៥ថ្ងៃប៉ុណ្ណោះ។ រីឯសាក្សីដែលសហព្រះរាជអាជ្ញាបានស្នើឡើងចំនួន៥រូបសម្រាប់ស-២១ (ដែលគេរំពឹងទុកថាសក្ខីកម្មរបស់ពួកគាត់មានភាពស្មុគស្មាញជាង ហើយត្រូវការពេលវេលាចំនួន២ថ្ងៃសម្រាប់សាក្សីម្នាក់ៗ) អាចត្រូវការពេលវេលាតែ១១ថ្ងៃប៉ុណ្ណោះ[27]។ សូម្បី តែមេធាវីការពារក្តីរបស់ នួន ជា ត្រូវបានអនុញ្ញាតឲ្យកោះហៅសាក្សីបន្ថែមទាក់ទងនឹងស-២១ ចំនួន៥នាក់ទៀត ក៏គេអាចបញ្ចប់សក្ខីកម្មសាក្សីបែបដូច្នេះបានដែរ មិនលើសពី១០ថ្ងៃទេ។

១៤- ដូច្នេះ ជាការពិបាកក្នុងការបង្ហាញនូវសិនណារីយ៉ូណាមួយដែលនៅក្នុងនោះ ការស្តាប់ចម្លើយសាក្សីទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះ អាចតម្រូវការពេលវេលាច្រើនជាង៨សប្តាហ៍ ហើយអាចមានលទ្ធភាពមួយដែលថាសក្ខីកម្មបែបដូច្នេះអាចនឹងត្រូវបានបញ្ចប់ក្នុងរយៈពេលតិចជាង៤សប្តាហ៍។ នៅក្នុងសវនាការមួយដែលគេរំពឹងថានឹងត្រូវចប់ក្នុងរយៈពេលចំនួនមួយឆ្នាំកន្លះនោះ ការពន្យារពេលចំនួន ៤ ទៅ៨សប្តាហ៍ គឺមិនមែនជា "ការពន្យារពេលយូរ" ដែលផ្តល់យុត្តិកម្មដល់ការបញ្ចប់ទីតាំងឧក្រិដ្ឋកម្មនៅមន្ទីរសន្តិសុខស-២១ និងនៅស្រុក១២ នោះឡើយ[28]។

---

[26] ពេលវេលារបស់ កសព ប៉ាន់ស្មានសម្រាប់សាក្សី ឬដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំដែលបានផ្តល់សក្ខីកម្មចាប់ពីពេលនោះមក គឺមានដូចតទៅ៖ ឡាយ បូនី Lay Bony (១ថ្ងៃ), ស៊ុំ ជា Sum Chea (0,៧៥ថ្ងៃ), ជុំ សុខា Chum Sokha (0,៧៥ថ្ងៃ), មុំ សំអឿន Mom Sam Oeurn (0,៧៥ថ្ងៃ), គង់ គីម Kung Kim (១ថ្ងៃ), ប៊ិជុយ ជីបសែ Pechuy Chipse (0,៧៥ថ្ងៃ), សុខ ឈិន Sokh Chhin (0,៧៥ថ្ងៃ), យឹម សុវណ្ណ Yim Sovann (0,៧៥ថ្ងៃ)។ ឯកសារលេខ **E218/2.1** កាលវិភាគ សវនាការដែលបានស្នើដោយ កសព, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២។ ពេលវេលាសរុបដែលបានប៉ាន់ស្មានដោយ កសព សម្រាប់សក្ខីកម្មរបស់បុគ្គលទាំង ៨ នាក់នេះគឺ ៦,៥ថ្ងៃ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់មានលទ្ធភាពបញ្ចប់សក្ខីកម្មរបស់ពួកខ្លួន ជាសរុបក្នុងចំនួន៧ថ្ងៃ។

[27] ឯកសារលេខ **E218/2.1** កាលវិភាគសវនាការដែលបានស្នើដោយ កសព, ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១២។

[28] មេធាវីការពារក្តីក៏បានពោលអះអាងផងដែរថា នៅក្នុងកំណត់សម្គាល់ជើងទំព័រមួយនៅក្នុងចម្លើយតប "គេត្រូវការពេលវេលាចំនួនបួនខែដើម្បីត្រៀមរៀបចំសម្រាប់សាក្សីបន្ថែមទាក់ទងនឹង ស-២១ ឲ្យមានប្រសិទ្ធភាព"។ ឯកសារលេខ **E163/5/1/4** ចម្លើយតប, កំណត់សម្គាល់ជើងទំព័រលេខ៣១។ សហព្រះរាជអាជ្ញាកត់សម្គាល់ថា ភាគីនានាបានត្រៀមរៀបចំសម្រាប់សវនាការនៅពេញមួយវិសាលភាពនៃសំណុំរឿង 00២/0១ នៅ ចន្លោះពេលនៃដីកាដំណោះស្រាយ (ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០) និងពេលដែលដីកាបំបែកកិច្ចដំណើរការនីតិវិធីត្រូវបានចេញ (ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១), គឺមានរយៈពេល តិចជាងពីរខែ មុនមានការចាប់ផ្តើមសវនាការ។ ដូចដែលត្រូវបានពិភាក្សាលម្អិតនៅក្នុងផ្នែក III.ឃ ខាងក្រោមនេះ បញ្ហានានាទាក់ទងនឹង ស-២១ គឺរហូតមកទល់ថ្ងៃនេះ ជាផ្នែកដ៏ទៀងទាត់មួយនៃសវនាការក្នុងសំណុំរឿង 00២/0១ រួមទាំង១២ថ្ងៃ នៃការផ្តល់សក្ខីកម្មដោយ ឌុច ផង ហើយវាពុំមានមូលហេតុតាមផ្លូវច្បាប់ណាមួយដែលក្រុមមេធាវីការពារក្តីតម្រូវឲ្យមានពេលវេលាបន្ថែម ដើម្បីត្រៀមរៀបចំសម្រាប់សាក្សីបន្ថែមដែលទាក់ទងនឹង ស-២១ នោះឡើយ។

១៥- អង្គជំនុំជម្រះសាលាដំបូងត្រូវធ្វើការវាយតម្លៃទៅលើភាពសមហេតុសមផលនៃការពន្យារពេលទាក់ទងទៅនឹងរយៈពេលទាំងមូលនៃសវនាការលើសំណុំរឿង០០២/០១ និងដោយប្រៀបធៀបទៅនឹងការពន្យារពេលរង់ចាំការវិនិច្ឆ័យសេចក្តីលើឧក្រិដ្ឋកម្មទាំងនោះ នៅក្នុងសវនាការលើកក្រោយទៀត។ ការពន្យារពេលដែលនឹងត្រូវបានភ្ជាប់ទៅនឹងការរង់ចាំរហូតដល់មានការចេញសាលក្រមនៅក្នុងសវនាការលើការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំ (ឬអាច រហូតដល់មានការបញ្ចប់បណ្តឹងសាទុក្ខទាំងអស់) និងបន្ទាប់មក ចាប់ផ្តើមសវនាការទីពីរ ដើម្បីវិនិច្ឆ័យទៅលើឧក្រិដ្ឋកម្មនានានៅស្រុក១២ និងស-២១ អាចមានការពន្យារពេលយូរជាង ការពន្យារពេលចំនួន៨សប្តាហ៍នៃសវនាការបច្ចុប្បន្ននេះទៅទៀត និងទំនងត្រូវប្រឈមនឹងផលវិបាកនានាទាក់ទងទៅនឹងសុខភាពរបស់ជនជាប់ចោទជាមិនខាន។ វាមិនមានបញ្ហាទេដែលថាអង្គហេតុទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មទាំងនេះនឹងត្រូវបានវិនិច្ឆ័យឆាប់ៗនេះ បើសិនជាធ្វើសវនាការក្នុងពេលឥឡូវនេះ ជាជាងទុកឲ្យមានការពន្យារពេល ទម្រាំនឹងមានសវនាការមួយដែលជាសម្មតិកម្ម (និងមិនទំនងជានឹងមានទេ) ទៅថ្ងៃអនាគត។

**គ. ជំនឿរបស់អង្គជំនុំជម្រះសាលាដំបូងដែលថាទីតាំងសម្លាប់មនុស្សនៅស្រុក១២ "ពុំជាប់ទាក់ទងជិតស្និទ្ធ" ទៅនឹងសំណុំរឿង០០២/០១ គឺជាការសន្និដ្ឋានលើអង្គហេតុមិនត្រឹមត្រូវ**

១៦- ចម្លើយតបនេះបង្កើតបានជាការអះអាងដែលមានលក្ខណៈចាប់បង្ខំមួយដែលពុំមានការជាប់ទាក់ទង ឬពុំមានខ្សែសង្វាក់រវាងការជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីតាំងសម្លាប់មនុស្សនៅស្រុក ១២ ប៉ុន្តែមិនមានការប៉ុនប៉ងទេ ដើម្បីពន្យល់ ឬបង្ហាញពីគោលជំហរនេះឡើយ[29]។ គឺប្រាប់ថា អំណះអំណាងរបស់មេធាវីការពារក្តីស្តីពីបញ្ហាដែលជាប់ទាក់ទងគ្នា ត្រូវបានកម្រិតចំពោះស-២១ ហើយពុំមានកិច្ចប្រឹងប្រែង ដើម្បីការពារដល់សេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនៅស្រុក១២ នោះឡើយ។

១៧- ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយទាក់ទងទៅនឹងស្រុក១២ ដែលសហព្រះរាជអាជ្ញាបានស្នើឲ្យដាក់បញ្ចូលនោះ គឺកថាខណ្ឌទី៦៩១ និង៦៩៣-៦៩៧[30]។ កថាខណ្ឌនានាខាងក្រោយនេះ មាន

[29] ឯកសារលេខ **E163/5/1/4** ចម្លើយតប, កថាខណ្ឌទី ២៥-២៦។

[30] ឯកសារលេខ **E163** សំណើរបស់សហព្រះរាជអាជ្ញាសុំបញ្ចូលទីតាំងឧក្រិដ្ឋកម្មបន្ថែមទៅក្នុងវិសាលភាពនៃការជំនុំជម្រះសំណុំរឿង ០០២/០១, ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២, កថាខណ្ឌទី ៥.ក ។

ចំណោងជើងថា "អ្នកជម្លៀសនៅស្រុក១២ នៅក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥" ហើយចោទប្រកាន់ថា នៅក្រោយថ្ងៃទី១៧ ខែមេសាឆ្នាំ១៩៧៥ភ្លាម អ្នកជម្លៀសមកពីភ្នំពេញ និងទីរួមខេត្តដទៃទៀត ត្រូវស្ថិតនៅក្រោមការសម្លាប់រង្គាលនៅតាមទីកន្លែងផ្សេងៗ នៅពាសពេញទាំងស្រុកនោះ[31]។ កថាខណ្ឌទី៦៩១ ក៏បានស្នើឲ្យមានការដាក់បញ្ចូលផងដែរ ពីព្រោះមានការចោទប្រកាន់ថា នៅក្នុងឃុំក្រាំងល្វា "នៅពេលដែលប្រជាជនត្រូវបានជម្លៀសចេញពីភ្នំពេញមកដល់ឃុំនេះ អង្គប្រជុំជាច្រើនត្រូវបានរៀបចំឡើង" និង "អ្នកជម្លៀសនោះដែលគេស្គាល់អត្តសញ្ញាណថាជាអតីតទាហានសាធារណរដ្ឋខ្មែរ ត្រូវបានយកទៅសម្លាប់ចោល"។

១៨- វាមិនមានបញ្ហាទេដែលថាទីតាំងសម្លាប់មនុស្សទាំងនេះ គឺ "ទាក់ទងគ្នាយ៉ាងជិតស្និទ្ធ" ទៅនឹងការជម្លៀសចេញពីទីក្រុងភ្នំពេញ ហើយបានឆ្លុះបញ្ចាំងនូវគោលបំណងឧក្រិដ្ឋនៃការផ្លាស់ប្តូរទីលំនៅប្រជាជនដោយបង្ខំលើកទី១។

## ឃ. អង្គជំនុំជម្រះសាលាដំបូងមានកំហុស ដោយខកខានមិនបានពិចារណាឲ្យបានត្រឹមត្រូវចំណោងទាក់ទងគ្នារវាង ស-២១ និងចោទប្រកាន់ពីអង្គហេតុដែលមានអត្ថិភាពនៅក្នុងសំណុំរឿង00២/0១

១៩- មេធាវីការពារក្តីក៏បានអះអាងផងដែរថា មានចំណោងទាក់ទងគ្នាមិនគ្រប់គ្រាន់មួយរវាង ស-២១ និង "ការចោទប្រកាន់ពីអង្គហេតុដែលមានអត្ថិភាពនៅក្នុងសំណុំរឿង00២/0១" ប៉ុន្តែ បានថ្លែងខុសពីវិសាលភាពនៃការចោទប្រកាន់ដើមដំបូងនៅក្នុងសំណុំរឿង00២/0១[32]។ តាមពិត ដូចដែលបានបង្ហាញខាងក្រោមនេះស្រាប់ ការចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ ដែលពីដំបូងបានដាក់បញ្ចូលនៅក្នុងសំណុំរឿង00២/0១ បានក្តោបគោលនយោបាយរបស់ បកក ចំពោះខ្មាំង, ដាក់គោលដៅទៅលើអតីតមន្ត្រី និងទាហានរបស់ លន់ នល់ និងបញ្ហាផ្សេងៗទៀតជាច្រើនដែលជាប់ទាក់ទង

[31] ឯកសារលេខ **D427** ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២0១0, កថាខណ្ឌទី ៦៩៣-៦៩៧។ សូមអាន កថាខណ្ឌទី៦៩៥ (ដែលបានពិពណ៌នាអំពីរបៀបដែល "ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភ្លាម" ពួកប្រធានភូមិត្រូវបានគេបញ្ជាឲ្យកត់ត្រាប្រវត្តិរូបរបស់ "ប្រជាជនថ្មីទាំងអស់ ដែលត្រូវបានជម្លៀសចេញពីទីក្រុងភ្នំពេញ" និងពួកដែលបានកំណត់ថាជា "ទាហាន, រដ្ឋការរបប លន់ នល់ និង មូលធននិយម" ត្រូវបានសម្លាប់ចោលនៅព្រៃទទឹង), កថាខណ្ឌទី៦៩៦ ("នៅចុងខែមេសា ឆ្នាំ១៩៧៥ ឬ ដើមខែឧសភា ឆ្នាំ១៩៧៥ ក្រុមគ្រួសារដែលត្រូវបានជម្លៀសចេញពី ទីក្រុងភ្នំពេញ ដែលបានមកដល់ក្នុងភូមិថ្មីខ្មែរ ឃុំត្បែងខ្ពស់ ត្រូវបាននាំទៅព្រៃស្រែវាល់ និងត្រូវបានសម្លាប់"), កថាខណ្ឌទី៦៩៧ (ដោយបានធ្វើការយោងពី "ការសម្លាប់ទ្រង់ទ្រាយធំស្រដៀងគ្នានេះ ដែលប្រហែលជាកើតឡើងនៅចុងខែមេសា ឬដើមខែឧសភា ឆ្នាំ១៩៧៥ នៅក្នុង ស្រុក១២" ចំពោះ "ប្រជាជនថ្មីដែលត្រូវបានគេកំណត់ថាជាអ្នករដ្ឋការ និងទាហាន សាធារណរដ្ឋខ្មែរ"។

[32] ឯកសារលេខ **E163/5/1/4** ចម្លើយតប, កថាខណ្ឌទី៣១។

ដោយផ្ទាល់ទៅនឹង ស-២១។ ជាលទ្ធផល ស-២១ គឺជាប្រធានបទមួយដែលសាក្សីជាច្រើនបានផ្តល់សក្ខីកម្មនៅក្នុងសវនាការលើសំណុំរឿង០០២/០១ និងឯកសារជាច្រើនទាក់ទងទៅនឹង ស-២១ ត្រូវបានទទួលយករួចហើយ។

២០- ផ្ទុយពីចម្លើយតបនេះ ការចោទប្រកាន់នានាកាលពីដំបូងនៅក្នុងសំណុំរឿងលេខ០០២/០១[33] រួមបញ្ចូលបញ្ហាជាច្រើនដែលជាប់ទាក់ទងដោយផ្ទាល់ទៅនឹងមន្ទីរស-២១។ នៅក្នុងផ្នែកទិដ្ឋភាពប្រវត្តិសាស្ត្រនៃដីកាដំណោះស្រាយបានដាក់បញ្ចូលក្នុងនោះនូវការវិវឌ្ឍនៃគោលនយោបាយរបស់ បកក ដែលអនុញ្ញាតឲ្យប្រើប្រាស់នូវ "ហិង្សាបដិវត្ត" ដើម្បីលុបបំបាត់ខ្មាំងរបស់បក្ស[34]។ នៅក្នុងដំណាក់កាលដំណើរការនីតិវិធីសវនាការ នួន ជា បានផ្តល់សក្ខីកម្មថា កម្ពុជាប្រជាធិបតេយ្យមាន "ការប្រុងប្រយ័ត្នខ្ពស់" ចំពោះ "ពួកក្បត់ដែលបានលួចជ្រៀតចូលក្នុងអង្គការ" និងថាត្រូវប្រើពេលវេលា "យូរដើម្បីស៊ើបអង្កេតប្រជាជន" បន្ទាប់ពីត្រូវបាន "ប្រមូលផ្តុំ និងបញ្ជូនទៅកាន់មន្ទីរស-២១" ដែលនៅទីនោះពួកគេអាចត្រូវបាន "ស្រង់យកចម្លើយសារភាព ឬចម្លើយបន្ថែមទៀត"[35]។

២១- នៅក្នុងផ្នែកស្តីពីរចនាសម្ព័ន្ធរដ្ឋបាល និងការប្រាស្រ័យទាក់ទងនៃដីកាដំណោះស្រាយមានរួមបញ្ចូលនូវការចោទប្រកាន់ផ្សេងៗទាក់ទងនឹងការចាប់ខ្លួន និងការសម្លាប់សមាជិកនៃគណៈកម្មាធិការមជ្ឈិម[36], សិទ្ធអំណាចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ ក្នុងការចេញបញ្ជាចាប់ខ្លួន, តួនាទីរបស់មន្ទីរស-៧១ ក្នុងការតាមឃ្លាំមើលសមាជិកបក្សដែលសង្ស័យ និងដឹកនាំចាប់ខ្លួន និងបញ្ជូនទៅកាន់មន្ទីរស-២១[37], រាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍[38] ស្តីពីបញ្ហាខ្មាំង, ពួកក្បត់ និងបញ្ហាសន្តិសុខផ្ទៃក្នុង[39], ការ

---

[33] សូមអានឯកសារលេខ **E124/7.1/corr-1** បញ្ជីកថាខណ្ឌ និងផ្នែកនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនិងការជំនុំជម្រះក្តីលើកដំបូងនៅក្នុងសំណុំរឿងលេខ០០២, ចុះថ្ងៃទី២៧ តុលា ២០១១ (បញ្ជីច្បាប់ដើមនៃកថាខណ្ឌដែលពាក់ព័ន្ធបន្ទាប់ពីដីកាសម្រេចបំបែកកិច្ចដំណើរការនៃនីតិវិធី)។

[34] ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កញ្ញា ២០១០, កថាខណ្ឌពីទី២១ និង២៣។

[35] ឯកសារលេខ **E1/26.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ, ចុះថ្ងៃទី១២ មករា ២០១២, ទំព័រទី៨-៩។

[36] ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ចុះថ្ងៃទី១៥ កញ្ញា ២០១០, កថាខណ្ឌទី៣៨, ៤៣ និង៥០។

[37] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី ៤១។

[38] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី ៥៣។

[39] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី ៧៦-៧៧។

ចាប់ខ្លួនកម្មាភិបាលនានាដែលត្រូវបានកោះហៅឲ្យមក "ប្រជុំរៀនសូត្រ" នៅភ្នំពេញ[40] និងការផ្សាយចម្លើយសារភាពឈ្លើយសឹកជនជាតិវៀតណាមដែលបានពីមន្ទីរស-២១[41]។

២២- នៅក្នុងផ្នែកស្តីពីរចនាសម្ព័ន្ធយោធានៃដីកាដំណោះស្រាយ មានរួមបញ្ចូលនូវការចោទប្រកាន់ផ្សេងៗទាក់ទងនឹងការទទួលខុសត្រូវរបស់កងទ័ពបដិវត្តកម្ពុជា ដើម្បី "ពារការគ្រប់គ្រងរបស់ បកក ប្រឆាំងនឹងពួកអ្នកដែលត្រូវយល់ឃើញថាជាខ្មាំង និងគេញនៅក្នុងកងកម្លាំងប្រដាប់អាវុធ នៅក្នុងជួរបក្ស និងក៏ដូចជានៅទូទាំងប្រទេសទាំងមូល"[42], ការទទួលខុសត្រូវនៃគណៈកម្មាធិការយោធារបស់បក្ស(ដែលក្នុងនោះរួមមាន នួន ជា)លើ "កិច្ចដំណើរការការងាររបស់មន្ទីរស-២១"[43], ការរាយការណ៍ជូនគណៈមជ្ឈិមស្តីពី "ការរកឃើញខ្មាំងផ្ទៃក្នុង"[44], ការបោសសំអាតខ្មាំងផ្ទៃក្នុងដែលត្រូវបានធ្វើឡើង "ក្រោមបញ្ជារបស់មជ្ឈិមបក្សនៃ បកក"[45], និងការប្រើប្រាស់មន្ទីរ ស-២១ ដើម្បី "សួរចម្លើយនិងចាប់ខ្លួនពួកអ្នកដែលគេចោទថាជាខ្មាំង"[46]។

២៣- ជាលទ្ធផលនៃបញ្ហាជាច្រើន ដែលត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពនៃសំណុំរឿងលេខ00២/0១ ពាក់ព័ន្ធនឹងមន្ទីរស-២១ និងគោលនយោបាយរបស់ បកក ក្នុងការលុបបំបាត់ខ្មាំងដែលមានចំនួន ១៤៥៣ យោងទៅលើ "មន្ទីរស-២១" នៅក្នុងកិច្ចដំណើរនីតិវិធីនៃសវនាការជំនុំជម្រះក្តី រហូតមកទល់នឹងពេលនេះ[47]។ ប្រធាននៃមន្ទីរស-២១ ឈ្មោះ កាំង ហ្គេកអ៊ាវ *ហៅ* ឌុច បានផ្តល់សក្ខីកម្មអស់រយៈពេលជាង១២ថ្ងៃ។ ផ្ទុយពីខ្លឹមសារនៅក្នុងចម្លើយតប គ្មានការកម្រិតជាដំកំភ្លួនណាមួយទៅលើវិសាលភាពនៃការសួរដេញដោលចំពោះរូបគាត់នោះទេ ហើយមេធាវីការពារក្តីបានប្រើរយៈពេល

[40] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី ៨៧-៨៨។

[41] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី ១១២។

[42] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី១១៧។

[43] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី ១២២-១២៣។

[44] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី១៣៧។

[45] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី ១៤៦-១៤៩។

[46] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី ១៤៥។

[47] ចំនួននេះបានមកពីការស្វែងរកមួយអំពីពាក្យថា "ស-២១" នៅក្នុងឯកសារប្រភេទ pdf នៃប្រតិចារិកនៃការជំនុំជម្រះក្តីនៅក្នុងសំណុំរឿងលេខ00២/0១ រហូតមកទល់ថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២0១២ (ថ្ងៃទី១៣១ នៃសវនាការ)។ ហេតុដូចនេះ មន្ទីរស-២១ ត្រូវបានបញ្ជាក់ជាមធ្យមចំនួន១១ដង ក្នុងមួយថ្ងៃៗ នៅក្នុងអម្លុងពេលនៃសវនាការ នៅក្នុងសំណុំរឿងលេខ00២/0១។

របស់ខ្លួនអស់ជិត២ថ្ងៃកន្លះ ដើម្បីសួរដេញដោល ឌុច[48] លើប្រធានបទស្តីពីការទទួលខុសត្រូវរបស់ នួន ជា ចំពោះមន្ទីរស-២១។ ជាបន្ថែមពីលើ ឌុច អង្គជំនុំជម្រះសាលាដំបូងបានស្តាប់ការផ្តល់សក្ខីកម្មរបស់នីវសា និងអង្គរក្ស នួន ជា ដែលបានផ្តល់សក្ខីកម្មថា ខ្លួនបានប្រគល់ចម្លើយសារភាពរបស់មន្ទីរស-២១ដែលទទួលបានពី ឌុច ជូនទៅ នួន ជា[49]។ សាក្សីនានាពីក្រសួងការបរទេសបានផ្តល់សក្ខីកម្មអំពីការទទួល និងប្រើប្រាស់របស់ អៀង សារី នូវចម្លើយសារភាពនានាដែលបានមកពីមន្ទីរស-២១ និងអំពីការទទួលខុសត្រូវរបស់គាត់ក្នុងការចាប់ខ្លួនកម្មាភិបាលករបស់ក្រសួងនេះ[50]។ មេដឹកនាំថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំ បានផ្តល់សក្ខីកម្មអំពីសេចក្តីរាយការណ៍ស្តីពីសភាពការណ៍ខ្មាំង នៅក្នុងតំបន់របស់ខ្លួន និងអំពីកម្មាភិបាលមូលដ្ឋានដែលត្រូវបានកោះហៅឲ្យមកកាន់ទីក្រុងភ្នំពេញ ហើយត្រូវបានបាត់ខ្លួន ដែលក្នុងនោះរួមទាំងមនុស្សជាច្រើនដែលត្រូវបានបញ្ជាក់អត្តសញ្ញាណនៅក្នុងបញ្ជីឈ្មោះរបស់មន្ទីរស-២១[51]។ លោកសាស្ត្រាចារ្យ David Chandler បានផ្តល់សក្ខីកម្មទាក់ទងបេសកកម្មរបស់មន្ទីរស-២១ និងអំពីទំនាក់ទំនងរបស់មន្ទីរនេះជាមួយមជ្ឈិមបក្សរបស់ បកក[52]។ ដោយបានស្តាប់អំពីគោលនយោបាយជាគន្លឹះ និងភាពជាប់ទាក់ទងជាមួយនឹងភ័ស្តុតាងដែលពាក់ព័ន្ធនឹងមន្ទីរស-២១ ដែលជាផ្នែកនៃសវនាការនេះ អង្គជំនុំជម្រះសាលាដំបូងមិនមានហេតុផលក្នុងការបដិសេធដោយសមហេតុសមផលចំពោះការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មនោះបានទេ ដោយសម្អាងថាមិនមានភាពជាប់ទាក់ទងគ្រប់គ្រាន់ទៅនឹង "អង្គហេតុចោទប្រកាន់ដែលមានស្រាប់ នៅក្នុងសំណុំរឿងលេខ០០២/០១ ឡើយ"។

---

[48] ក្រុមមេធាវីការពារក្តីរបស់ នួនជា បានសួរដេញដោល ឌុច អស់រយៈពេលមួយម៉ោង នៅថ្ងៃទី៣ ខែមេសា ឆ្នាំ២០១២ (ឯកសារលេខE1/58.1), ពេញមួយថ្ងៃនៅថ្ងៃទី៤ និងទី៥ មេសា ២០១២ (ឯកសារលេខ E1/59.1 & លេខE1/60.1) និងមួយម៉ោងបន្ថែមទៀតនៅថ្ងៃទី១០ មេសា ២០១២ (ឯកសារលេខE1/62.1)។

[49] ឯកសារលេខ **E1/63.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ថ្ងៃទី១៨ មេសា ២០១២,ទំព័រ៥៤។ ឯកសារលេខ **E1/64.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ថ្ងៃទី១៩ មេសា ២០១២, ទំព័រ១៤-១៩។

[50] ឯកសារលេខ **E1/67.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ, ថ្ងៃទី២៤ មេសា ២០១២, ទំព័រទី៥០-៥២ [ ពីម៉ោង14:20:52 ដល់ម៉ោង 14:27:22] (សូ ហុង So Hong)។ ឯកសារលេខ **E1/102.1** ប្រតិចារិកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ,ថ្ងៃទី ៦ សីហា ២០១២, ទំព័រទី៩៣-៩៥ [ពីម៉ោង15:29:34 ដល់ម៉ោង 15:35:06], កថាខណ្ឌទី ១០៣-១០៤ [ពីម៉ោង15:54:35 ដល់ម៉ោង 15:59:28] (សួង ស៊ី គឿន Suong Sikoeun)។ ឯកសារលេខ **E1/98.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ, ថ្ងៃទី៣០ កក្កដា ២០១២, ទំព័រទី៤៥-៥០ [ពីម៉ោង11:36:45 ដល់ម៉ោង 11:53:44] (ភី ភួន Phy Phuon)។

[51] ឯកសារលេខ **E1/83.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ,ថ្ងៃទី៧ មិថុនា ២០១២, ទំព័រទី៦-១៤ និងទី២៨-៣២។ ឯកសារលេខ **E1/84.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ, ថ្ងៃទី១១ មិថុនា ២០១២, ទំព័រទី៣៧-៤៨។ ឯកសារលេខ **E1/88.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ, ថ្ងៃទី១៩ មិថុនា ២០១២, ទំព័រទី៨០-៩២ និង១០២-១០៤។

[52] ឯកសារលេខ **E1/91.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ, ថ្ងៃទី១៨ កក្កដា ២០១២, ទំព័រទី១១-១១១៣ និងទី១១៧-១១៨។ ឯកសារលេខ **E1/93.1**ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ, ថ្ងៃទី១៩ កក្កដា ២០១២, ទំព័រទី១៣៣-១៣៧។ ឯកសារលេខ **E1/93.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីនៃសវនាការ, ថ្ងៃទី១៨ កក្កដា ២០១២, ទំព័រ៤៧។

២៤- ជាងនេះទៅទៀត ផ្ទុយពីខ្លឹមសារនៅក្នុងចម្លើយតប[53] ការចោទប្រកាន់នានាចំពោះ, ក្រុមគោលដៅនៃពួកអតីតមន្ត្រី និងទាហានរបស់សាធារណរដ្ឋខ្មែរ ត្រូវបានដាក់បញ្ចូលនៅក្នុងវិសាលភាពដើមដំបូងនៃសំណុំរឿងលេខ០០២/០១ និងមិនមែនទើបតែក្លាយទៅជាមានការជាប់ទាក់ទងដោយសារសេចក្តីសម្រេចនាពេលថ្មីៗនេះរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការបន្ថែមនូវទីតាំងឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ តែប៉ុណ្ណោះនោះទេ។ ឧទាហរណ៍ដូចជា កថាខណ្ឌទី១៤៨ នៃដីកាដំណោះស្រាយបានចោទប្រកាន់ថា នៅក្នុងរយៈពេលភ្លាមៗបន្ទាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥, "បញ្ជារឲ្យសម្លាប់ពួកអតីតមន្ត្រីនៃសាធារណរដ្ឋខ្មែរ និងជនដទៃទៀតដែលត្រូវបានគេចាត់ទុកថាជាខ្មាំង- ត្រូវបានអនុវត្តដោយបុគ្គលិកយោធាដែលឆ្លើយតបទៅនឹងលេខាភូមិភាគនានា ដែលបានទទួលបញ្ជាមកពីគណៈកម្មាធិការអចិន្ត្រៃយ៍"[54]។ ផ្នែកនៃដីកាដំណោះស្រាយដែលទាក់ទងទៅឯកសារយោង ស្តីពីការជម្លៀសចេញដោយបង្ខំលើកទី១ បានបង្ហាញឲ្យឃើញថាគោលបំណងនៃការបញ្ជូនឲ្យចេញពីទីក្រុងភ្នំពេញ គឺដើម្បីរកអត្តសញ្ញាណ និងលុបបំបាត់ចោលនូវពួកទាហានរបស់ លន់ នល់ និងបានចោទប្រកាន់នៅក្នុងពេលបញ្ជូនចេញនោះ "ពួកទាហាន លន់ នល់ ត្រូវបានស្គាល់អត្តសញ្ញាណ ដោយសារការសាកសួរ និងត្រូវបានគេយកចេញទៅដាច់ដោយឡែកពីប្រជាជនដែលចាកចេញពីទីក្រុង"[55]។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងគួរបានពិនិត្យពិចារណាផងដែរអំពីទំនាក់ទំនងគ្នារវាងមន្ទីរស-២១ និងការផ្តោតមុខសញ្ញារបស់ បកក ទៅលើពួកមន្ត្រី និងទាហានរបស់ លន់ នល់។

២៥- ចំពោះរឿងនោះ ឌុចបានផ្តល់សក្ខីកម្មនៅក្នុងការជំនុំជម្រះក្តីនេះថា ក្រុមដំបូងគេបង្អស់នៃ "ពួកខ្មាំងដែលជាគន្លឹះ" ដែលត្រូវបានផ្តោតមុខសញ្ញាដោយ បកក នៅក្រោយឆ្នាំ១៩៧៥នោះ គឺ "ពួកអតីតទាហាន និងមន្ត្រីនៃរបប លន់ នល់" ដែលគាត់បានឃើញមាននៅក្នុងបញ្ជីមួយចំនួននៃពួកអ្នកទោសដូចខាងលើនេះ នៅមន្ទីរស-២១ និងថាពួកអតីតទាហាននិងមន្ត្រីរបស់ លន់ នល់ ទាំងនោះ ត្រូវបានគេសម្លាប់នៅក្នុងអម្លុងពេលតាំងពីមុនការតែងតាំងរូបគាត់ឲ្យធ្វើជាប្រធានមន្ទីរ ស-២១ មកម្ល៉េះ[56]។ ការផ្តល់សក្ខីកម្មរបស់ ឌុច នេះ ត្រូវបានបញ្ជាក់ដោយបញ្ជីសម្លាប់មួយរបស់មន្ទីរ ស-២១ ចុះកាល

---

[53] ឯកសារលេខ **E163/5/1/4** ចម្លើយតប, កថាខណ្ឌទី៣៤។

[54] ឯកសារលេខ **D427** ដីកាដំណោះស្រាយ, ថ្ងៃទី១៥ កញ្ញា ២០១០, កថាខណ្ឌទី១៤៨។

[55] ឯកសារលេខ **D427** *ដូចគ្នានឹងខាងលើ*, ត្រង់កថាខណ្ឌទី២៣៤, ២៤៣, ២៥៤។

[56] ឯកសារលេខ **E1/52.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ថ្ងៃទី២១ មីនា ២០១២, ទំព័រទី២៥-២៦។

បរិច្ឆេទខែមីនា ឆ្នាំ១៩៧៦ ដែលក្នុងនោះមានបញ្ជាក់អត្តសញ្ញាណនៃពួកទាហាន មន្ត្រី និងបងប្អូនរបស់ពួកគេចំនួន១៦២នាក់ ដែលត្រូវបានសម្លាប់ចោលនៅមន្ទីរ ស-២១[57]។

២៦- ជាចុងក្រោយ មេធាវីការពារក្តីបានតវ៉ាថាគោលនយោបាយរបស់ បកក ក្នុងការលុបបំបាត់ខ្មាំង (ដែលរួមបញ្ចូលជនទាំងឡាយណាដែលជាប់ទាក់ទងជាមួយនឹងរបប លន់ នល់ ផង) គឺជាចំណុចស្នូលនៃសេចក្តីសម្រេចឲ្យជម្លៀសចេញពីទីក្រុងភ្នំពេញ ដោយបានអះអាងថា "ភ័ស្តុតាងគាំទ្រតែមួយគត់ចំពោះការពោលអះអាងនេះ គឺមានតែការដកស្រង់ដ៏ខ្លីនូវសម្តីរបស់ ឌុច តែម្នាក់ឯងតែប៉ុណ្ណោះ"[58]។ តាមពិតការ "ពោលអះអាងនេះ" ត្រូវបានបង្ហាញ ដោយភ័ស្តុតាងយ៉ាងច្បាស់ និងដែលគួរឲ្យជឿនៅក្នុងការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១ ដែលនៅក្នុងនោះរួមមានចម្លើយរបស់ជនជាប់ចោទខ្លួនឯងផង និងមេដឹកនាំបក្សដ៏ទៃទៀត[59] ឯកសារនានារបស់ បកក ដែលរៀបរាប់អំពីគោលបំណងនៃការជម្លៀសចេញ[60] និងសក្ខីកម្មរបស់ពួកយោធារបស់ បកក ដែលធ្លាប់បានចូលរួមនៅក្នុងការជម្លៀសនេះ[61]។ ការជម្លៀសចេញពីភ្នំពេញ គឺគ្រាន់តែជាជំហានទីមួយប៉ុណ្ណោះ នៅក្នុងការខិតខំប្រឹងប្រែងរបស់ បកក ដើម្បីត្រួតត្រាលើប្រជាជន និងលុបបំបាត់រាល់ពួកអ្នកដែលពួកគេ

---

[57] ឯកសារលេខ **E3/1539** បញ្ជីអ្នកទោស ស-២១ ដែលមានចំណងជើងថា "ឈ្មោះអ្នកទោសដែលបានស្លាប់នៅមន្ទីរស-២១ ក", ចុះកាលបរិច្ឆេទខែមីនា ១៩៧៦។

[58] ឯកសារលេខ **E163/5/1/4** ចម្លើយតប, កថាខណ្ឌទី៣០, លេខយោងជើងទំព័រលេខ៤៥។

[59] ឯកសារលេខ **E1/14.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ថ្ងៃទី២២ វិច្ឆិកា ២០១១, ទំព័រទី១០៣-១០៤ និង ១០៧-១០៩។ (ចម្លើយរបស់ នួន ជា ថា មូលហេតុដែលនាំឲ្យធ្វើសេចក្តីសម្រេចជម្លៀសប្រជាជនចេញពីភ្នំពេញ រួមមាន ការព្រួយបារម្ភថា ពួកទាហាន លន់ នល់ដែល "ពួនលាក់ខ្លួននៅក្នុងទីក្រុងភ្នំពេញនៅឡើយ" ហើយនិង "សកម្មភាពបំផ្លិចបំផ្លាញដោយពួកក្បត់ដែលបានលបជ្រៀតចូលនៅក្នុងបក្ស")។ ឯកសារលេខ**D199/26.2.35** សន្និសីទសារព័ត៌មានរបស់ ប៉ុល ពត នៅទីក្រុងប៉េកាំង, ចុះថ្ងៃទី៣ តុលា ១៩៧៧, ភាសាអង់គ្លេស ត្រង់លេខ ERN ENG 00390927 (ដែលថ្លែងថា ប្រជាជនអ្នករស់នៅក្នុងទីក្រុង ត្រូវបានជម្លៀសចេញ ដើម្បីធ្វើការវាយកំទេច " អង្គការចារកម្មរបស់ខ្មាំងគ្រប់ប្រភេទ")។ ឯកសារលេខ **E3/550** ការធ្វើសម្ភាសន៍ អៀង សារី ដោយកាសែត Newsweek, អត្ថបទចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ១៩៧៥, ជាភាសាអង់គ្លេស ត្រង់លេខ ERN 00087603 (ដែលថ្លែងថា មូលហេតុដែលនាំឲ្យមានការជម្លៀសចេញនោះ គឺដោយសារការរកឃើញនូវគំរោងផែនការរបស់ពួកភ្នាក់ងារ និងទាហាន របស់លន់ នល់ ដែលគ្រោងនឹងបង្កឲ្យមានបញ្ហានៅក្នុងក្រុងភ្នំពេញ)។ ឯកសារលេខ **E3/196** សន្ទរកថារបស់នួនជា ថ្លែងទៅកាន់បក្សពលករកុម្មុយនិស្តនៃប្រទេសដាណឺម៉ាក Communist Workers' Party of Denmark, ចុះកាលបរិច្ឆេទខែកក្កដា ឆ្នាំ១៩៧៨, ជាភាសាអង់គ្លេសត្រង់លេខ ERN 00762402។

[60] *សូមអាន* ឧទាហរណ៍ដូចជា ឯកសារលេខ **E3/5** ទស្សនាវដ្តីទង់បដិវត្ត, ចេញផ្សាយនៅខែសីហា ១៩៧៥, ជាភាសាអង់គ្លេសត្រង់លេខ ERN 00401486។

[61] ឯកសារលេខ **E1/140.1** ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការ, ថ្ងៃទី៥ វិច្ឆិកា ២០១២, ទំព័រទី១៦-១៨, ទី២៦, និងទី២៩-៣៣ ឯកសារលេខ **E3/419** កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់ អៀង ផាន IENG Phan, ចុះថ្ងៃទី២៣ វិច្ឆិកា ២០០៩, ជាភាសាអង់គ្លេស ត្រង់លេខ ERN 00411004។

យល់ថាជាខ្មាំង និងការជាប់ទាក់ទងរបស់ បកក ជាមួយនឹងមន្ទីរ ស-២១ និងគោលនយោបាយរបស់ បកក ស្តីពីខ្មាំងដែលមិនអាចឲ្យប្រកែកបានទេ។

## IV. សេចក្តីសន្និដ្ឋាន

២៧- អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សហព្រះរាជអាជ្ញា ស្នើដោយគោរពដល់អង្គជំនុំជម្រះមេត្តាច្រានចោលនូវរាល់អំណះអំណាងដែលបានធ្វើឡើងដោយក្រុមមេធាវីការពារក្តីរបស់ នួន ជា នៅក្នុងចម្លើយតបរបស់ខ្លួន ដោយសម្រេចថា បណ្តឹងសាទុក្ខភ្លាមៗនេះរបស់សហព្រះរាជអាជ្ញា គឺអាចទទួលយកបាន និងមេត្តាផ្តល់ដំណោះស្រាយដូចតាមសំណើនេះដោយអនុគ្រោះ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០១២ | លោក យ៉េត ចរិយា<br>សហព្រះរាជអាជ្ញារង | ភ្នំពេញ | [signature] |
| | លោក William SMITH<br>សហព្រះរាជអាជ្ញារង | | [signature] |